ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តាឧណាមប្រជារាស្ត្រខ្មែរ
សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង០៨ និង ៣០នាទី ព្រឹកសាលសវនាការទី៩ ដោយមានសមាសភាព៖

ក្រុមប្រឹក្សាដំនុំជម្រះ

-លោក [redacted] ប្រធានក្រុម

-លោក [redacted] ចៅក្រមក្រុមប្រឹក្សា

-លោក [redacted] ចៅក្រមក្រុមប្រឹក្សា

តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីដំនុំជម្រះ

សំណុំរឿងព្រហ្មទណ្ឌលេខ ១៣៨០ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១ ដែលមាន៖

ជនជាប់ចោទឈ្មោះ [redacted] **រដ្ឋម៉ានី ហៅ ម៉ៅ** ភេទប្រុស អាយុ៣០ឆ្នាំ ជនជាតិខ្មែរ មុខរបរលក់ដូរ ទីកន្លែងកំណើត [redacted] ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្នស្នាក់នៅ ផ្ទះលេខ២៣៦ ផ្លូវលំ ភូមិខ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ **នៅលីវ** ឪពុកឈ្មោះ [redacted] **សុង** "រ" ម្តាយឈ្មោះ [redacted] **សាម៉ែ** "រ" ជានីតិជន ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

-ដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ **១៧៣៨** "ភ" ដ.ព.ស ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

ជាប់ចោទពីបទ៖ **ទំលោភសេពសន្ថវៈ** ប្រព្រឹត្តនៅចំណុច ផ្ទះលេខ១៩ដេ ផ្លូវលំ ភូមិខ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា **២៣៩** នៃក្រមព្រហ្មទណ្ឌ ។

-មេធាវី [redacted] មានការិយាល័យក្រុមមេធាវី**ប្រុន**ដ៍ តាំងនៅអគារលេខ២២ ផ្លូវលេខ២៤២កែង១០៧ សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] **រដ្ឋម៉ានី** ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ម៉ារឿន** ភេទស្រី កើតឆ្នាំ១៩៩៦ ទីលំនៅបច្ចុប្បន្នស្នាក់នៅ ផ្ទះលេខ១៩ដេ (ផ្ទះល្វែងSN) ផ្លូវបេតុង ភូមិខ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

Scanned with CamScanner

សាលាដំបូងរាជធានីភ្នំពេញ
-សាលក្រមព្រហ្មទណ្ឌ
លេខ ៥២០ "ច" ក្រ
ចុះថ្ងៃទី ១២.០៧.២០២២
-សំណុំរឿងព្រហ្មទណ្ឌ
លេខ ១៣៨០
ចុះថ្ងៃទី ២៤.០៣.២០២១
-សំណុំរឿងស៊ើបសួរ
លេខ ១០៤២
ចុះថ្ងៃទី ២៥.០៣.២០២១
-សំណុំរឿងដំនុំជម្រះ
លេខ ៣៧៦៤
ចុះថ្ងៃទី ២៨.១០.២០២១

-បានឃើញ របាយការណ៍សំយោគលេខ ០៧២/២១ លេខកូដករណី ០៦៨ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១ របស់ស្នងការនគរបាលរាជធានីភ្នំពេញផែនការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងការងារយេនឌ័រការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ **១០៧៣ អ.ឃ.ដ** ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានស្តាពរលេខ **៣១៤៥ អ.ឃ.ដ** ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១ របស់ តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ **៤៨៦៧ "ភ" ដ.ដ** ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ របស់ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ ។

អត្ថហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង១០ និង០០នាទីយប់ បន្ទាប់ពីឈ្មោះ [redacted] **ម៉ារឿន** ភេទស្រី អាយុ២៥ឆ្នាំ និងឈ្មោះ [redacted] **រដ្ឋម៉ានី ហៅ ម៉ៅ** ភេទប្រុស អាយុ៣០ឆ្នាំ មកពីលក់កាហ្វេវិញ ឈ្មោះ [redacted] **រដ្ឋម៉ានី ហៅ ម៉ៅ** បានជូនគូដណ្តឹងឈ្មោះ [redacted] **ម៉ារឿន** មកសម្រាកនៅ ផ្ទះលេខ១៩ដេ ផ្លូវលំ ភូមិខ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។ ពេលមកដល់ផ្ទះ ឈ្មោះ [redacted] **រដ្ឋម៉ានី ហៅ ម៉ៅ** បានលួងលោមសុំរួមភេទ ជាមួយឈ្មោះ [redacted] **ម៉ារឿន** ប៉ុន្តែឈ្មោះ [redacted] **ម៉ារឿន** មិនព្រម ខណៈនោះឈ្មោះ [redacted] **រដ្ឋម៉ានី ហៅ ម៉ៅ** បានចាប់សង្កត់ឈ្មោះ [redacted] **ម៉ារឿន** នៅលើកន្ទេលបន្តប់ទទួលភ្ញៀវមិនឲ្យរើបម្រះរួច និងបានធ្វើសកម្មភាពរំលោភលើឈ្មោះ [redacted] **ម៉ារឿន** រហូតបានសម្រេច ។

នាពេលសវនាការ

-អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **រដ្ឋម៉ានី ហៅ ម៉ៅ** បានឆ្លើយថា៖ ខ្លួន និងឈ្មោះ [redacted] **ម៉ារឿន** ភេទស្រី ត្រូវជាគូរដណ្តឹងនឹងគ្នាដែលបានភ្ជាប់ពាក្យ កាលពីខែកក្កដា ឆ្នាំ២០២០ ក្រោយពីភ្ជាប់ពាក្យរួច ហើយឈ្មោះ [redacted] **ម៉ារឿន** បានមកស្នាក់នៅផ្ទះលេខ១៩០ ផ្លូវលំ ភូមិខ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ជាផ្ទះឪពុក-ម្តាយនាងប្រគល់ឲ្យ ហើយខ្លួនបន្ទាប់ពីជួយលក់ដូរឥវ៉ាន់ឪពុក-ម្តាយរួចខ្លួនក៏បានទៅស្នាក់នៅជាមួយឈ្មោះ [redacted] **ម៉ារឿន** នៅក្នុងផ្ទះខាងលើតែពេលយប់ទេ ព្រោះថានាងស្នាក់នៅក្នុងផ្ទះនេះម្នាក់ឯង ហើយឪពុក-ម្តាយខ្លួនក៏បានយល់ព្រមឲ្យខ្លួនទៅដេកស្នាក់នៅ និងបានជួយមើលថែនាងផង ។ រាល់ពេលដែលខ្លួនទៅដេកជាមួយនាងនៅផ្ទះខាងលើ ក្នុងនាមខ្លួនជាគូរដណ្តឹងខ្លួនបានសុំនាងរួមភេទបានច្រើនដងរាល់ពេលយប់ ដោយមានការយល់ព្រមពីនាង គឺរាល់ការរួមភេទជាមួយគ្នា ដោយពុំដែលមានការគំរាមកំហែង ឬបង្ខិតបង្ខំអ្វីទេ ។

-អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ម៉ារឿន** បានឆ្លើយថា៖ កាលពីអំឡុងខែមិថុនា ឆ្នាំ២០២០ ឪពុក-ម្តាយរបស់ឈ្មោះ [redacted] **រដ្ឋម៉ានី** ភេទប្រុស អាយុ៣០ឆ្នាំ មានទីលំនៅ ផ្ទះលេខ២៣៦ ផ្លូវលំ ភូមិខ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ បានចូលមកជួបម្តាយខ្លួនដើម្បីស្តីដណ្តឹងខ្លួន ដោយឪពុក-ម្តាយខ្លួនទារថ្លៃបណ្តាការចំនួន ១០,០០០$ (**មួយម៉ឺនដុល្លារ**) **អាមេរិក** តែឪពុក-ម្តាយខាងប្រុសឲ្យតែចំនួន ៥,០០០$ (**ប្រាំពាន់ដុល្លារ**) **អាមេរិក** ប៉ុណ្ណោះ ព្រោះគេមានកន្លែងឲ្យកូនរកស៊ី និងជួយហៅភ្ញៀវឲ្យ៣០តុ ក្រោយពីត្រូវរ៉ូវគ្នាហើយ លុះមកដល់ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២០ ពិធីភ្ជាប់ពាក្យមកដល់ និងបានកំណត់រៀប

អាពាហ៍ពិពាហ៍នៅថ្ងៃទី០៧ ខែ កុម្ភៈ ឆ្នាំ២០២១ ហើយគាត់បានកក់មុនចំនួន ២,០០០$ (ពីរពាន់) **ដុល្លារអាមេរិក** ពេលភ្ជាប់ពាក្យហើយខាងប្រុសនៅផ្ទះរបស់គេ ចំណែកខ្លួននៅផ្ទះខ្លួន តែខាងប្រុសគាត់ឧស្សាហ៍ចេញចូលមកលេងផ្ទះខ្លួន លុះមកដល់ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង១០យប់ ឈ្មោះ [redacted] **រដ្ឋម៉ានី** ដែលជាគូរដណ្តឹងខ្លួនបានមកផ្ទះខ្លួន ហើយដេកនៅទីនេះ ហើយគាត់បានចាប់រំលោភខ្លួនមួយលើក ពេលរំលោភរួចគាត់បានគំរាមខ្លួនថាមិនបាច់ប្តឹងទេ ទឹកដីនេះជារបស់គាត់ ហើយខ្លួនក៏មិនហ៊ានប្តឹង នៅលើកទី២ មិនចាំថ្ងៃខែឆ្នូ ឆ្នាំ២០២០ ពេលយប់ឈ្មោះ [redacted] **រដ្ឋម៉ានី** ក៏បានចាប់រំលោភខ្លួននៅផ្ទះខ្លួនម្តងទៀត ហើយគំរាមខ្លួនដូចលើកទី១ដែរ និងលើកទី៣ ពេលដែលពួកខ្លួនទៅលេងឆ្លងឆ្នាំនៅកំពង់សោម គាត់បម្រុងចាប់រំលោភខ្លួនម្តងទៀត តែខ្លួនស្រែកឲ្យបងប្អូនជួយទាន់ ក្រោយមកទៀតឈ្មោះ [redacted] **រដ្ឋម៉ានី** ឃើញខ្លួន និងឪពុក-ម្តាយខ្លួនគាត់ចេះតែគេចវេសរហូត លុះមកដល់ថ្ងៃទី០៦ ខែ មករាឆ្នាំ២០២១ ឪពុក-ម្តាយខាងកូនប្រុស បានមកផ្ទះខ្លួន គាត់បានសួរឪពុក-ម្តាយខ្លួនថាការកើតអត់ ? ឪពុក-ម្តាយខ្លួនឆ្លើយតបថា "**ការកើតបងឲ្យលុយបង្គ្រប់មក**" ដើម្បីឪពុក-ម្តាយខ្លួនយកចាត់ចែងកក់ឥវ៉ាន់ ឪពុក-ម្តាយកូនប្រុសថា "**ដល់ថ្ងៃការចាំឲ្យ**" ព្រោះទំនៀមទំលាប់ស្រុកគាត់ ពេលនោះក៏មានការអន់ចិត្តគ្នាទៅវិញទៅមក ហើយគាត់ក៏បានទារលុយដែលពួកគាត់ឲ្យពេលភ្ជាប់ពាក្យចំនួន ២,០០០$ (**ពីរពាន់ដុល្លារ**) **អាមេរិក** វិញ ឪពុក-ម្តាយខ្លួនមិនឲ្យ ហើយពួកគាត់ក៏ចេញទៅវិញបាត់ទៅ ។

-តាមសេចក្តីសន្និដ្ឋានរបស់លោក [redacted] ដែលជាមេធាវីការពារឲ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ កូនក្តីរបស់យើងខ្ញុំឈ្មោះ [redacted] **រដ្ឋម៉ានី ហៅ ម៉ៅ** និងដើមចោទឈ្មោះ [redacted] **ម៉ារឿន** គឺមានទំនាក់ទំនងជាគូដណ្តឹងនឹងគ្នា ដែលក្រុមគ្រួសារទាំងសងខាងបានរៀបចំពិធីភ្ជាប់ពាក្យឲ្យអ្នកទាំងពីរដែលមានពិធីសំពះសែន ចងដៃ ផ្ទឹម ហែរជំនូន បងប្អូនចាស់ទុំចូលរួម និងមានរៀបកម្មវិធីទទួលភ្ញៀវស្មើរតែដូចនឹងពិធីរៀបការដែរ ។ ម្យ៉ាងទៀតកូនក្តីរបស់យើងខ្ញុំ និងដើមចោទឈ្មោះ [redacted] **ម៉ារឿន** មិនទាន់បានចុះសំបុត្រអាពាហ៍ពិពាហ៍នោះគឺដោយសារតែម្តាយរបស់ឈ្មោះ [redacted] **ម៉ារឿន** ថាចាំឲ្យម្តាយ និងឪពុករបស់កូនក្តីយើងខ្ញុំបង្គ្រប់លុយថ្លៃទឹកដោះជាមុនសិន ទើបឲ្យកូនក្តីយើងខ្ញុំចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយនិងដើមចោទ ។ ក្រោយពីមានការអនុញ្ញាត និងយល់ព្រមអាណាព្យាបាលរបស់ដើមចោទបានអោយកូនក្តីយើងខ្ញុំ ចូលទៅរស់នៅជាមួយឈ្មោះ [redacted] **ម៉ារឿន** ជាមួយគ្នាក្នុងផ្ទះដែលជាកន្លែងកើតហេតុ ដោយការរស់នៅជាមួយគ្នានេះគឺមានភាពស្និតស្នាល ល្អក្លែន និងរស់នៅយ៉ាងចុះចម្រុងគ្នា ហើយស្រលាញ់គ្នាណាស់ ទាំងពេលប្រកបរបររកស៊ីលក់ការហ្វេជាមួយគ្នាក៏ដោយ លើសពីនេះទៅទៀតរាល់ពេលរួមភេទជាមួយគ្នាគឺធ្វើឡើងដោយស្ម័គ្រចិត្តនឹងគ្នា គ្មានការបង្ខិតបង្ខំនោះទេ ។ ដែលនេះបានបញ្ជាក់ថាការរស់នៅសព្វថ្ងៃឈ្មោះ [redacted] **ម៉ារឿន** និងកូនក្តីយើងខ្ញុំគឺប្រៀបបាននឹងប្តីប្រពន្ធបាត់ទៅហើយ ។ ស្របពេលនេះដែរឈ្មោះ [redacted] **ប៊ុនហឿន** ដែលត្រូវជាបងប្រុសបង្កើតរបស់ដើមចោទក៏បានបំភ្លឺផងដែរពាក់ព័ន្ធនឹងការរស់នៅរបស់កូនក្តីយើងខ្ញុំ និងឈ្មោះ [redacted] **ម៉ារឿន** ដែលរស់នៅយ៉ាងចុះសម្រុងជាមួយគ្នាដូចប្តីនឹងប្រពន្ធ ។ រាល់អង្គហេតុដែលបានលើកឡើងខាងលើនេះ គឺមានភាពផ្ទុយគ្នាបាត់ទៅហើយ ដែលដើមចោទបានចោទថា កូនក្តីរបស់យើងខ្ញុំ ដែលជាគូដណ្តឹងបានប្រព្រឹត្តបទល្មើសរំលោភដោយប្រើហិង្សា ព្រោះថាមិនមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់អំពីការប្រព្រឹត្ត ដែលបង្ហាញអោយឃើញស្លាកស្នាមរបួសកើតចេញពីការចាប់រំលោភដោយប្រើអំពើហិង្សានោះទេ គួបផ្សំជាមួយភាពមិនស៊ីចង្វាក់គ្នារវាងចម្លើយរបស់ដើមចោទ និងចម្លើយរបស់បងប្រុសរបស់ខ្លួនផង ។ ដែលនេះបញ្ជាក់

យ៉ាងច្បាស់ថាការចោទប្រកាន់នេះគឺខ្វះនូវធាតុផ្សំបទល្មើស ដែលជាមូលដ្ឋានក្នុងការចោទប្រកាន់កូនក្តីរបស់យើងខ្ញុំ និងវិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ដូច្នេះដើម្បីចោទប្រកាន់ និងផ្តន្ទាទោសជនណាម្នាក់ គឺត្រូវបង្ហាញពីពិរុទ្ធភាពឲ្យហួសវិមតិសង្ស័យ ។ យើងខ្ញុំក៏សូមបញ្ជាក់ផងដែរថា មូលហេតុដែលដើមចោទធ្វើការប្តឹងកូនក្តីយើងខ្ញុំ គឺដោយសារតែការពិភាក្សាគ្នារឿងថ្លៃទឹកដោះរវាងម្តាយឪពុកខាងប្រុស និងខាងស្រីមិនត្រូវគ្នាទើបធ្វើឲ្យកើតមានការខឹងគ្នា ។ ហេតុនេះយើងខ្ញុំក្នុងនាមជាមេធាវីការពារសិទ្ធិសូមធ្វើការសន្និដ្ឋានជារួមថា កូនក្តីយើងខ្ញុំឈ្មោះ [redacted]**រដ្ឋម៉ានី ហៅ ម៉ៅ** មិនបានប្រព្រឹត្តិអំពើដូចបានចោទប្រកាន់របស់ដើមចោទនោះទេ ដោយហេតុថាកូនក្តីយើងខ្ញុំ និងឈ្មោះ [redacted]**ម៉ារឿន** គឺមានទំនាក់ទំនងជាគូរដណ្តឹងនឹងគ្នា ដែលការលើកឡើងនេះគឺគ្មានមូលដ្ឋាន និងភស្តុតាងគ្រប់គ្រាន់បង្ហាញពីសកម្មភាពរំលោភសេពសន្តវៈនោះទេ ។ ដោយរឿងនេះគឺជារឿងទំនាស់ផលប្រយោជន៍សុទ្ធសាធ ដែលកើតចេញពីគ្រួសារខាងដើមចោទ មកលើគ្រួសាររបស់កូនក្តីយើងខ្ញុំ ទើបបង្កើតជាគំនិតទុច្ចរិតចោទប្រកាន់ឈ្មោះ [redacted]**រដ្ឋម៉ានី ហៅ ម៉ៅ** យ៉ាងអយុត្តិធម៌ជាទីបំផុត ។ ជាចុងក្រោយយើងខ្ញុំស្នើសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចឲ្យកូនក្តីរបស់យើងខ្ញុំ រួចផុតបទចោទ ។

-**តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖** ឆ្លងតាមអង្គសវនាការ អំណានតាមចម្លើយរបស់ជនជាប់ចោទ អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ស្នើសុំឲ្យតុលាការសម្រេចតាមអង្គហេតុ និងអង្គច្បាប់ជាក់ស្តែង ។

-សម្តីចុងក្រោយរបស់ជនជាប់ចោទ សុំឲ្យតុលាការសម្រេចឲ្យរួចផុតបទចោទ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ ។

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ ។

-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា ។

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

<u>**សំអាងហេតុ**</u>

-**តាមមាត្រា ២៣៩** នៃក្រមព្រហ្មទណ្ឌចែងថា៖ **បទរំលោភសេពសន្តវៈ**: គ្រប់អំពើបញ្ចូលអង្គជាត តាមបែបណាក៏ដោយ ឬអំពើបញ្ចូលឧបករណ៍ណាមួយទៅក្នុងអង្គជាត ដែលប្រព្រឹត្តទៅលើអ្នកដ៏ទៃ ទោះបីជាភេទដូចគ្នា ឬមិនដូចគ្នាក៏ដោយ ដោយការប្រើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬដោយការឆ្នក់ឱកាស គឺជាបទរំលោភសេពសន្តវៈ ។

បទរំលោភសេពសន្តវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

នីតិភាពនៃការរួមភេទត្រូវបានកំណត់ចាប់ពីអាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ឡើងទៅ ។

-តាមហេតុការណ៍ប្រព្រឹត្តនៃបទល្មើស៖ តាមបណ្តឹងរបស់ឈ្មោះ [redacted]**ម៉ារឿន** ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ បានឲ្យដឹងថា៖ កាលពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២០ ខ្លួន និងឈ្មោះ [redacted]**រដ្ឋម៉ានី** បានភ្ជាប់ពាក្យជាមួយគ្នា និងមានគំអាងរៀបការជាមួយគ្នានៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២១ ។ ក្រោយពីភ្ជាប់ពាក្យហើយ ឪពុកម្តាយរបស់ខ្លួនបានប្រគល់ផ្ទះមួយកន្លែងឲ្យខ្លួនស្នាក់នៅ ដែលមានទីតាំងនៅជិតផ្ទះរបស់ឈ្មោះ [redacted]**រដ្ឋម៉ានី**

ដែលជាគូដណ្តឹង ហើយផ្ទះនេះទៀតសោត គឺខ្លួនស្នាក់នៅតែម្នាក់ឯងប៉ុណ្ណោះដោយសារតែខ្លួនត្រូវរៀននៅភ្នំពេញ ហើយឪពុកម្តាយរបស់ខ្លួននៅឯខេត្តព្រះសីហនុ ។

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **រដ្ឋម៉ានី** នៅមន្ត្រីនគរបាលយុត្តិធម៌ តំណាងអយ្យការ ចៅក្រមស៊ើបសួរ និងពេលសវនាការ បានឆ្លើយបដិសេធអំពីការចោទប្រកាន់របស់តំណាងអយ្យការ ថារូបខ្លួនពិតជាពុំបានប្រព្រឹត្តអំពើ **រំលោភសេពសន្តវៈ** នោះទេ ដោយមូលហេតុថា ខ្លួន និងឈ្មោះ [redacted] **ម៉ារឿន** គឺជាគូដណ្តឹងនឹងគ្នា រងចាំតែថ្ងៃរៀបអាពាហ៍អាពាហ៍ ហើយក្នុងអំឡុងពេលនោះផងដែរក៏បានស្នាក់នៅជាមួយគ្នា រួមភេទជាមួយគ្នាជាច្រើនលើកច្រើនសារ ដោយគ្មានការបង្ខិតបង្ខំ និងមានការដឹងលឺពីម្តាយឪពុកទាំងសងខាង ដោយពុំដូចការចោទប្រកាន់របស់តំណាងអយ្យការឡើយ ។ ចម្លើយរបស់ជនជាប់ចោទ បើធៀបទៅនឹងសាក្សីឈ្មោះ [redacted] **ប៊ុនហឿន** ដែលជាបងប្រុសបង្កើតរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ម៉ារឿន** គឺប្រហាក់ប្រហែលគ្នាស៊ីតស៊ីងតែទាំងអស់ ហេតុដូច្នេះតុលាការ គប្បីពិចារណា និងស្វែងរកយុត្តិធម៌ជូនតាមអង្គហេតុជាក់ស្តែង ។

-ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ម៉ារឿន** នៅមន្ត្រីនគរបាលយុត្តិធម៌ បានឆ្លើយថាខ្លួននៅតែការរក្សាការប្តឹងទៅលើឈ្មោះ [redacted] **រដ្ឋម៉ានី** ថាចាប់រំលោភខ្លួន និងសូមឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមផ្លូវច្បាប់ និងទាមទារប្រាក់សេវាកម្មផ្លូវច្បាប់ នៃសំណងជម្លីចិត្ត ចំនួន ១០.០០០ (**មួយម៉ឺន**) **ដុល្លារអាមេរិក** ដដែល ការប្តឹងចោទប្រកាន់នេះ ពុំមានភស្តុតាង ឬសាក្សីណាមួយដាក់បន្ទុកជាក់លាក់ច្បាស់លាស់ដើម្បីឱ្យតុលាការជឿជាក់ឈានដល់ការសម្រេចផ្តន្ទាទោសជនជាប់ចោទបានឡើយ ។ ម៉្យាងដើមបណ្តឹងក៏ទទួលស្គាល់ថាខ្លួនថាជនជាប់ចោទ និងខ្លួនពិតជាគូដណ្តឹងនឹងគ្នា ហើយបានធ្វើពិធីភ្ជាប់ពាក្យហៅបងប្អូន និងញាតិមិត្តមកចូលរួមវិធីទៀតផង ។

-តាមសេចក្តីសន្និដ្ឋានរបស់លោក [redacted] ដែលធ្វើសេចក្តីសន្និដ្ឋានស្នើសុំឱ្យតុលាការសម្រេចរួចផុតបទចោទលើកូនក្តីខ្លួននោះ មានមូលហេតុ និងហេតុផលសមរម្យ អាចឱ្យតុលាការលើកយកមកពិចារណា និងសម្រេចតាមបាន ។

-តាមសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ បានធ្វើសេចក្តីសន្និដ្ឋានដោយស្នើសុំឱ្យតុលាការសម្រេចតាមអង្គហេតុ និងអង្គច្បាប់ជាក់ស្តែង សំណូមពរនេះតុលាការ និងសម្រេចតាមភស្តុតាង និងតាមច្បាប់ ។

-តាមចម្លើយរបស់ជនជាប់ចោទ អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ មានភាពស៊ីសង្វាក់គ្នាបង្ហាញឱ្យឃើញយ៉ាងជាក់ថាជនជាប់ចោទឈ្មោះ [redacted] **រដ្ឋម៉ានី** ភេទប្រុស អាយុ៣០ឆ្នាំ ពុំបានប្រព្រឹត្តអំពើ **រំលោភសេពសន្តវៈ** ប្រព្រឹត្តនៅ ប្រព្រឹត្តនៅចំណុច មុខផ្ទះលេខ១៩ដេ ផ្លូវលំ ភូមិខ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា **២៣៩** នៃក្រមព្រហ្មទណ្ឌ នោះទេ គឺដោយសារតែទំនាស់ផលប្រយោជន៍រវាងម្តាយឪពុកខាងប្រុសដែលមានការយឺតយ៉ាវក្នុងការបង្គ្រប់លុយផ្ទៃទឹកដោះ មកម្តាយឪពុកម្តាយខាងស្រី ដែលជាដើមហេតុធ្វើឱ្យម្តាយខាងស្រីមានការខឹងសម្បាយ៉ាងខ្លាំង កើតជារឿងដាក់ពាក្យបណ្តឹងប្តឹងមកលើឈ្មោះ [redacted] **រដ្ឋម៉ានី** ។ នៅក្នុងអំឡុងពេលដែលរួមរស់នៅជាមួយគ្នានោះ គឺអ្នកទាំងពីរបានស្នាក់នៅ និងមានការរួមភេទជាមួយគ្នាច្រើនលើកច្រើនសារ ដោយគ្មានការបង្ខិតបង្ខំដូចជាប្តីប្រពន្ធដែរ ជាមូលហេតុ

នាំឲ្យអ្នកទាំងពីរមានការយល់ចិត្តគ្នារងចាំតែថ្ងៃរៀបអាពាហ៍ពិពាហ៍តែប៉ុណ្ណោះ ហើយក្នុងពេលនោះដែរអ្នកទាំងពីរ ក៏បានកំណត់ថ្ងៃរៀបអាពាហ៍ពិពាហ៍ហើយផងដែរ ។

-តាមចម្លើយរបស់ជនជាប់ចោទ និងចម្លើយរបស់ជនរងគ្រោះ បានបញ្ជាក់ថាជនជាប់ចោទ ចាប់រំលោភសេពសន្ថវៈដោយមានការគំរាមពីជនជាប់ចោទថា មិនចាប់ប្តឹងទេទឹកដីនេះជាទឹកដីរបស់គាត់ **(ជនជាប់ចោទ)** និងរំលោភសេពសន្ថវៈ លើកទី២គំរាមដូចលើកទី១ដែរ ដោយមានរយៈពេល១ខែម្តងតែប៉ុណ្ណោះ ហើយជនរងគ្រោះពុំបានដាក់ពាក្យបណ្តឹងប្តឹងភ្លាមៗនោះទេ ទាល់តែមានការទាស់ពាក្យសម្តីគ្នា និងមានការអាក់អន់ចិត្តនឹងគ្នារវាងចាស់ទុំ **(សាច់ញាតិខាងប្រុស និងខាងស្រី)** ទើបឈានដល់ជនរងគ្រោះប្តឹងជនជាប់ចោទ ប៉ុន្តែជនជាប់ចោទបានឆ្លើយបដិសេធថា ខ្លួនពុំបានចាប់បង្ខំជនរងគ្រោះរំលោភសេពសន្ថវៈនោះទេ គឺមានការរួមភេទដោយស្ម័គ្រចិត្ត ដោយពុំមានការបង្ខិតបង្ខំ និងគំរាមកំហែងអ្វីឡើយ ហេតុដូច្នេះតុលាការគប្បីពិនិត្យពិចារណា និងសម្រេចតាមច្បាប់ ។

-គ្មានភស្តុតាងដាក់បន្ទុក និងគ្មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **រដ្ឋម៉ានី ហៅ ម៉ៅ** ភេទប្រុស អាយុ៣០ឆ្នាំ ពីបទៈ **រំលោភសេពសន្ថវៈ** ប្រព្រឹត្តនៅចំណុច មុខផ្ទះលេខ១៩ដេ ផ្លូវលំ ភូមិខ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា **២៣៩** នៃក្រមព្រហ្មទណ្ឌ យោងមាត្រា ៣៨ វាក្យខ័ណ្ឌ ៦ ដែលបានចែងថាៈ **"វិមតិសង្ស័យត្រូវបានជាផលប្រយោជន៍ដល់ជនជាប់ចោទ"** ។

ហេតុដូច្នេះសម្រេច

ឲ្យឈ្មោះ [redacted] **រដ្ឋម៉ានី ហៅ ម៉ៅ** ភេទប្រុស អាយុ២០ឆ្នាំ **រួចផុតបទចោទ** ពីបទៈ **រំលោភសេពសន្ថវៈ** ប្រព្រឹត្តនៅចំណុច មុខផ្ទះលេខ១៩ដេ ផ្លូវលំ ភូមិខ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា **២៣៩** នៃក្រមព្រហ្មទណ្ឌ ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ នៅចំពោះមុខជនជាប់ចោទឈ្មោះ [redacted]**រដ្ឋម៉ានី ហៅ ម៉ៅ** និងមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ តែកំពាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ម៉ារឿន** និងប្រកាសជាសាធារណៈនៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២២ គូភាគីមានសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងរយៈពេលច្បាប់កំណត់ ។

ក្រឡាបញ្ជីសវនាការ	ចៅក្រមប្រឹក្សា	ចៅក្រមប្រឹក្សា	ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
ហត្ថលេខា និងត្រា	ហត្ថលេខា និងត្រា	ហត្ថលេខា និងត្រា	ហត្ថលេខា និងត្រា

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ១០កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២២

ក្រឡាបញ្ជី

[redacted]